ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តមណ្ឌលគិរី
រដ្ឋបាលក្រុងសែនមនោរម្យ
គណៈកម្មាធិការលទ្ធកម្ម

លេខ : ០៦៨/១៦.....ស.ជ.ណ

សែនមនោរម្យ, ថ្ងៃទី.០៨...ខែ.វិច្ឆិកា.....ឆ្នាំ២០១៦

សេចក្តីជូនដំណឹង
ស្តីពី

ការអញ្ជើញចូលរួមពិគ្រោះថ្លៃការងារជួសជុលផ្លូវលំក្រាលគ្រួសក្រហម
ប្រវែង ១៩០០ម x ៥ម ដាក់លូ ០២កន្លែង និងស្តារលូ ០២កន្លែង

រដ្ឋបាលក្រុងសែនមនោរម្យ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋបាលក្រុងសែនមនោរម្យ នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលផ្លូវលំក្រាលគ្រួសក្រហមប្រវែង ១៩០០ម x ៥ម ដាក់លូ ០២កន្លែង និងស្តារលូ ០២កន្លែង ស្ថិតនៅភូមិអូរស្ពានសង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ។

រដ្ឋបាលក្រុងសែនមនោរម្យ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ដែលមានដាក់លក់នៅអង្គភាពលទ្ធកម្មក្រុងសែនមនោរម្យ មានអាសយដ្ឋានភូមិដើមស្រល់ សង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចាប់ពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ ០៩៧ ៩៧៣ ០២៧៨) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គតាពលទ្ធកម្មក្រុង យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ០៨ នឹង ៣០នាទីព្រឹក ។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គតាពលទ្ធកម្មក្រុង តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨ នឹង៣០នាទីព្រឹក ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃ បានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ប្រធានគណៈកម្មាធិការលទ្ធកម្ម

ឈ្មុង - ទិបុល

ចម្លងជូន ៖
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមណ្ឌលគិរី (ដើម្បីជូនជ្រាប)
- ឯកសារ កាលប្បវត្តិ